គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA – CKIMHRDA- CSD - CWCC - GENEROUS - HROTP - IDA
KID - KKKHRA - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - PDP - PJJ - TASK FORCE - VIGILANCE
#3, St. 158, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Cambodia, Tel/Fax: 351415 E-mail: chrac@forum.org.kh

# Press Statement of CHRAC on the occasion of celebration of 58th anniversary of International Human Rights Day, December 10th

The occasion of International Human Rights Day, December 10th, 2006 is the 58th anniversary of the universal declaration on Human Rights that was passed on December 10th, 1948. The Cambodian Human Rights Action Committee (CHRAC), a coalition of 23 NGO members, extends its appreciation for the efforts of the Royal government for making a number of progresses for the respects for human rights. However, we have noticed a great deal of impediments in the application of principles of human rights, democracy and policy for reduction of poverty such as:

## I. Land Issues:

The Action Committee noted that land disputes which lead to human rights violation remain as a critical issue and as one of the reasons that affect seriously the livelihood of people such as right to life, right to appropriate shelter, and right to adequate food etc. The eviction of people from their households so as to claim land for powerful, private company and businesspersons without appropriate compensation for people made people become poor, in addition, they have lost their job or occupation in making income generation. Virtually, the forced eviction against people more than 1000 families in Sambok Chab village and 168 families in Preah Monivong A.B community in Phnom Penh earlier and presently, presently hey are facing seriously with the living and health issues.

The concerns over the large scale of economic land concession remains continue and some land concessions are larger than the land size determined under the land law and those land concessions were not assessed on environmental and poor community affect. Obviously, the people of 205 families in CHIKHOR Leu Commune, Sre Ambel District, Koh Kong Province are being suffered because of their land has been given as economic land concession to private company by royal government. Further more, a number of huge land concessions have affected natural resources such as forestry wildlife and religious belief of indigenous people etc and including leading to losing of occupation of people who making a living based on forestry and losing of right to consumption of natural resources and so on.

**Mr. Thun Saray**, Chairman of CHRAC and President of ADHOC said that “Royal government shall guarantee the land and natural resources of Cambodia shall manage in a way that it will support the living and welfare of many people who live in Cambodian rural areas. Before offering economic land concession, royal government shall study on environmental impact before hand and shall implement the policy for land concession. In order to solve the landlessness and the land grabbing which are increasing and worsening, it is necessary to have a strong commitment from national level.

## II. Corruption issue:

CHRAC concerns over the corruption which is the critical issue that cause poverty. The corruption is spreading all over the country especially the corruption in the judicial system, the majority of cases have been intervened and taken action according the law by authorities or by human right workers are finished in court, a number of other court cases have been dropped the charge without trial. Perpetrators have bought justice from the court and police officials and the court officials have tried to reconciliation the criminal offenses between victims and perpetrators in aim to gain benefits from that reconciliations. Recently, the World Bank has found the corruption connected with amount of USD 11.9 million in 43 projects of the royal government. In the same time, Economic Institute of Cambodia has evaluated in its researching findings that "the informal expenses paid by the private enterprises were approximately USD330 million in 2005. This evaluation report has also stated that State has lost the income tax for the amount of USD 400 million in 2005. In 2006 the authorities have prevented and detained not to run a clean hand campaign activity in support of Anti-corruption for seven cases in Phnom Penh including the confiscation of dissemination materials. These factors are contradictory to the triangle policy of royal government in its third term headed by Prime Minister Hun Sen who considered the anti-corruption as the core of the triangle policy for the growth, employment, equity and effectiveness.

The present corruption has been noted that it has destroyed in all sectors in society such as: the corruption in the field of politics has destroyed democracy and good governance through the violation of formal procedures. The corruption in the election and in the legislature has reduced the responsibility and representation for making decision. The corruption in the court has made destruction against the rule of law. The corruption in the public administration has made no justice in providing services, in addition, it has weakened the competence of government institutions such as the procedure are not respected, human resources have no chance to share knowledge and the public offices have not been bought and sold. In the same time, the corruption has destroyed the legitimacy of government and the values of democracy are not followed.

The CHRAC would like to recommend the government as below in order to speed up with the Anti-corruption law.

1- The draft anti-corruption law shall create the independent anti-corruption unit. This unit shall be given a mandate to do investigation against any individual regardless political tendencies or any interest. Truly, the anti-corruption unit can receive advice or direction from anti-corruption supreme council but the secretary general and general secretariat shall maintain the constant control over this unit. This point including the autonomous budget and allow the annual expenses.
2- Anti-corruption unit shall have power to investigate independently. The investigator of corruption must be judicial police with the power and duties as a police and those police shall not be responsible before the prosecutor but they shall be responsible only before the Secretary General. This point is of great importance in order to protect the competency of Anti-corruption unit. They shall have independent mandate in doing investigation of any corruption case and shall not be prevented by the office of prosecutor.
3- Declaration of property by civil servants shall be done, once again, this point, we would like to request Samdech, Prince, Princess, and His/Her Excellencies the members of the National Assembly shall be the model. While Samdech, Prince, Princess, His/Her Excellencies the members of the National Assembly who received the vote of confidence the vote owners, this means that Samdech, Prince, Princess, His/Her Excellencies shall be completely transparent in your financial works. In the same time, in order for

Anticorruption unit can perform its tasks, the declaration of property must be included the properties of spouse officials and of children as well and the document for declaration of properties shall be allowed to open amid the investigation.

4- Last point: Anti-Corruption law shall contain the provision on criminal offense in consistent with the criminal code and criminal procedure code. This point means that the provision on the confidentiality shall be firm and strong in order to protect victim and witness. In relation to the investigation, this law shall contain the special manner. If this Anti-corruption law shall not be in accordance the international standard as mentioned above then this to law will not be different from paper tiger, it seems looking strong but the reality, it has no power.

**III- Issue of freedom of expression:**

Concern over the restriction and suppression on the freedom of expression or rallies, the use of violence against the peaceful demonstration, strike remain continue, the request for demonstration or rallies seldom receive authorization, demonstration or rallies have always been dispersed by the forces of local authorities. These are the key obstacles in application of values of respect for human rights and democracy as guaranteed in constitution.

The Action Committee request for a full respect of law which are in force in particular the law that guarantee the freedom for organizing a peaceful demonstration and the freedom of expression in order to promote rule of law and the processes of democracy in Cambodia.

**IV. Right to protection of human right workers:**

The works of staff members of non-governmental organizations especially the works of the staff members of human rights organizations are of great deal of contributions in building of peace, meaningful and perpetual development of the country. Even though, human rights activists and leaders of civil society organizations were released in the beginning of 2006 but still we have noted that there still exist of threats against human rights activists who investigated the cases of human rights violations, and most recently, there is a threat against Mr. Pen Bunna, the Provincial Coordinator of ADHOC in Mondul kiri province. For some cases, the authorities have prevented human rights activist not to investigate in the location of incidents of human rights violations especially the cases of land disputes. Some human rights activists have been accused of inciting people to protest against the decision of authorities but the authorities do not recognize that their decisions have violated the land of people and people were not satisfied with that decision then they rallied to oppose against that decision but the authorities just turned to blame human rights workers.

The Action Committee urges the royal government to realize and consider the works of civil society are lawfully and valuable for Khmer society and to guarantee the works of human rights organizations free from any intimidations from the government officials, in addition, it is vital that human rights organizations and civil society organizations can fulfill their tasks without any prevention and any intimidation for their safety.

The Action Committee hopes that the civil society and the royal government can work as cooperation partners in construction of Cambodia in achieving of rule of law and promotion of respect for human rights.

**V. Political violence and election:**

The election f commune council is the important phase toward the construction of democracy in Cambodia. However, the Action Committee noticed that the killing, intimidation, threat and the political harassment are happening while Cambodia is preparing the commune council election to be held in 2007. The threats have seriously affected the environmental security and the freedom of participation of people in election and in political activities in the pre-election period. Obviously, since the dissemination of information on election, verification of voter list and the registration of voters in 2006 till today, there are violent cases in relation to the activists of political party in three provinces: Kampong Cham, Prey Veng and Kratje, within that violence, there were three killing cases (three people were killed) who were the party men of Sam Rainsy Party in which two killing cases in Prey Veng and another one killing case in Kampong Cham and one attempted killing case against the party man of Funcipec in Kratje. The wounded cases against the party men of Sam Rainsy Party in which two cases happened in Prey Veng province and another happened in Kampong Cham province. The dropping case of Funcinpec logo happened in Kampong Cham. All party men who were killed were the popular men in their respective areas. At last, they have conducted activities and brought people to take part in their political parties and actively participated in the phase of verification of voter list and in the registration processes such as the distribution of form number 1018 and taking of photo for registration.

The Action Committee understands that if the political violence remains continue, it would be a major obstacle affecting the processes of the forthcoming liberal democratic and fair election. As for, people as well as election candidate will afraid to join the political activities in particular during the communal election campaigns.

**Dr. Kek Galabru**, President of Licadho said that " in order to reduce the human rights abuses and to prevent people not to commit the abuses of human rights, the only way is to legally punish against whoever committed the human rights abuses ".

The Action Committee requests the royal government to take the urgent and effective actions so as to protect and prevent the happening of political violence and to guarantee the rights and freedom of people. For Judiciaries, Armed forces and competent authorities shall be independent and neutral in fulfillment of the tasks in aim to create a good environment during the election.

**VI. Issues of poverty:**

Poverty is the major issue in our society. The poverty is not because of the bad deed from the former birth, the poverty is the issues of human rights, the abuses of human rights are the causes and the consequences of poverty as well. The land abuses and eviction are the critical human rights violations and made become poor and even poorer. Some said that because of the people are lazy that is why people are poor, they do not recognize that people has no chance, most of the time, people make a lot of efforts but they do not receive income as expected.

The eradication of poverty does not only waiting for the country having much incomes, some countries have much incomes but those incomes are fallen into the grip of the small group and the country remains the same poor. This point is because of having no equality in society. The reduction of poverty is not only based on humanitarian donation, there shall exist of proper development plan and pay much attention in effective implementation of the plan. The Action Committee understands that in order to reduce

the poverty, there shall be approaches such as cooperatively fighting against corruption, bribery, exploitation and promotion of participation from women in the livelihood of families and in every social works as well. Fostering of constructions of all infrastructures which are the vital needs of people at large, promotion of respect for human rights and freedom of people … etc

Phnom Penh, December 9th, 2006


*For more information, please contact:*

| | | |
|---|---|---|
| Mr. Thun Saray | Chairman of CHRAC and President of ADHOC | Tel: 016 880 509 |
| Dr. Kek Galabru | President of LICADHO | Tel: 012 940 645 |
| Mr. Sok Sam Oeun | Executive Director of CDP | Tel: 012 901 199 |
| Mr. Yong Kimeng | President of PDP-Center | Tel: 016 828 211 |
| Mrs. Nay Dina | Executive Director of KID | Tel: 012 924 286 |


Unofficial translation

**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA
KID - KKKHRA - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - PDP - PJJ - TASK FORCE - VIGILANCE
#3, St. 158, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Cambodia, Tel/Fax: 351415 E-mail: chrac@forum.org.kh


# សេចក្តីថ្លែងការណ៍រួមរបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម
# ក្នុងឱកាសប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ខួបលើកទី៥៨

នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ឆ្នាំ២០០៦ ខួបលើកទី៥៨ នូវសេចក្តីថ្លែងការណ៍ជាសកលស្តីពី សិទ្ធិមនុស្ស ដែលត្រូវបានអនុម័តកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស និង ច្បាប់ចំនួន ២៣ សូមសំដែងនូវការសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការជួយឱ្យមានការរីកចំរើន ខ្លះៗនៅការគោរពសិទ្ធិមនុស្ស ។ ទោះបីជាយ៉ាងណាក៏ដោយ យើងឃើញនៅមានឧបសគ្គរាំងស្ទះជាច្រើនដល់ដំណើការអនុវត្តគោលការណ៍គោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និង គោលការណ៏កាត់បន្ថយភាពក្រីក្រ មានជាអាទិ៍ៈ

## I- បញ្ហាដីធ្លី

គណៈកម្មាធិការប្រព្រឹត្តិកម្មកត់សំគាល់ថា បញ្ហាទំនាស់ដីធ្លីដែលដឹកនាំទៅរកការរំលោភសិទ្ធិមនុស្ស នៅតែជាបញ្ហាចំបងដ៏សំខាន់មួយ និង ជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀត ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវជំរកសមរម្យ សិទ្ធិមានអាហារហូបចុកគ្រប់គ្រាន់ ។ល។ ការបណ្តេញប្រជាពលរដ្ឋឱ្យចាកចេញពីផ្ទះសំបែង ដើម្បីយកដីប្រគល់ឱ្យអ្នកមានអំណាច ឬ ក្រុមហ៊ុន នាយទុន ដោយមិនមានសំណងសមរម្យជូនប្រជាពលរដ្ឋ ដែលជាហេតុធ្វើឱ្យគាត់ក្លាយទៅជាអ្នកក្រខ្លាមមួយរំពេច ថែមទាំងបាត់បង់ការងារ ឬអាជីព ក្នុងការរកប្រាក់ចំណូល ស្របពេលជាមួយគ្នានេះតែម្តង ។ ជាក់ស្តែង ដូចជាការបណ្តេញដោយបង្ខំទៅលើប្រជាពលរដ្ឋ ចំនួនជាង ១០០០ គ្រួសារ នៅភូមិសំបុកចាប និង ១៦៨ គ្រួសារនៅ សហគមន៍ពេទ្យព្រះមុន្នីវង្សអាបេ ក្រុងភ្នំពេញ កន្លងទៅនេះ ដែលបច្ចុប្បន្នពួកគាត់កំពុងតែជួបប្រទះនូវបញ្ហាជីវភាពរស់នៅ និង បញ្ហាសុខភាពធ្ងន់ធ្ងរ ។

ការព្រួយបារម្ភចំពោះការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមានទំហំធំៗ ទៅឱ្យផ្នែកឯកជននៅតែបន្ត ហើយដីសម្បទានខ្លះមានទំហំលើសពីច្បាប់ភូមិបាលបានកំណត់ ហើយថែមទាំងមិនត្រូវបានគេវាយតម្លៃ អំពីផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និង សហគមន៍ក្រីក្រទេ ។ ជាក់ស្តែងប្រជាពលរដ្ឋចំនួន ២០៥ គ្រួសារនៅឃុំជីខលើ ខេត្តកោះកុង កំពុងតែរងទុក្ខលំបាក ដោយសារតែដីរបស់គាត់ត្រូវបានរាជរដ្ឋាភិបាលផ្តល់សម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន ។ ពេលនេះពួកគាត់កំពុងតែតវ៉ាទាមទាដីរបស់ពួកគាត់មកវិញ តែរហូតមកដល់ពេលនេះ ក្រុមហ៊ុននៅតែបន្តការឈូសឆាយលើដីរបស់ពួកគាត់ដដែល ដោយមិនទាន់មានដំណោះស្រាយសមរម្យណាមួយជូនដល់ពួកគាត់ទេ ។ លើសពីនេះទៅទៀតការផ្តល់ដីសម្បទានធំ ៗ មួយចំនួនបានធ្វើឱ្យប៉ះពាល់ដល់ ធនធានធម្មជាតិ ដូចជា ព្រៃឈើ សត្វព្រៃ ជំនឿសាសនារបស់ជនជាតិដើម ជាដើម ព្រមទាំងបាត់បង់នូវមុខរបរប្រជាពលរដ្ឋ ដែលរស់នៅអាស្រ័យព្រៃឈើ និង សិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ ។ល។

លោក **ធន សារាយ** ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និង ជាប្រធានសមាគមអាដហុកបាន មានប្រសាសន៏ថា "រាជរដ្ឋាភិបាលត្រូវធានាថា ដីធ្លី និង ធនធានធម្មជាតិ របស់កម្ពុជា ត្រូវបានចាត់ចែងតាមវិធីមួយ

ដើម្បីទ្រទ្រង់ជីវភាពរស់នៅ និង សុខមាលភាពរបស់ប្រជាពលរដ្ឋភាគច្រើន ដែលរស់នៅទីជនបទក្នុងប្រទេសកម្ពុជា ។ មុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ច រាជរដ្ឋាភិបាលត្រូវតែសិក្សាពីផលប៉ះពាល់សហគមន៏ជាមុន និង ត្រូវអនុវត្តឱ្យបាននូវគោលការណ៍ដីសម្បទាន" ។ "ដើម្បីដោះស្រាយបញ្ហាភាពគ្មានដីធ្លី និងការរំលោភលើសិទ្ធិដីធ្លី ដែលកាន់តែរីករាលដាល និង ធ្ងន់ធ្ងរឡើង ៗ វាត្រូវការជាចាំបាច់ឱ្យមានការប្តេជ្ញាចិត្តនៅថ្នាក់ជាតិ ឱ្យបានខ្លាំងក្លាជាងមុន "។

## II. <u>បញ្ហាអំពើពុករលួយ</u>

គណៈកម្មាធិការប្រព្រឹត្តិកម្មមានការព្រួយបារម្ភចំពោះបញ្ហាអំពើពុករលួយ ដែលជាចំណុចដ៏សំខាន់ចំបងមួយផ្សេងទៀត ដែលបង្កអោយកើតមាននូវភាពក្រីក្រ ។ អំពើពុករលួយកំពុងកើតមាននៅទូទាំងប្រទេសជាពិសេសគឺអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ ដោយហេតុថារឿងក្តីភាគច្រើន ដែលត្រូវបានធ្វើអន្តរាគមន៏ និង ចាត់វិធានការផ្លូវច្បាប់ដោយអាជ្ញាធរក្តី ឬ ដោយក្រុមសិទ្ធិមនុស្សក្តីត្រូវបានបញ្ចប់នៅតុលាការ រឿងក្តីមួយចំនួនត្រូវបានលើកលែងការចោទប្រកាន់ដោយគ្មានការជំនុំជំរះ ។ ជនល្មើសបានទិញយុត្តិធម៌ពីតុលាការ មន្ត្រីប៉ូលីស និង តុលាការ បានព្យាយាមផ្សះផ្សារឿងក្តីព្រហ្មទណ្ឌ រវាងជនរងគ្រោះ និងជនល្មើស ដើម្បីទទួលកំរៃពីការផ្សះផ្សានេះ ។ ថ្មី១នេះ ធនាគារពិភពលោកបានរកឃើញអំពើពុករលួយ ដែលពាក់ព័ន្ធនឹងទឹកប្រាក់ ចំនួន ១១,៩ លានដុល្លារ នៅក្នុងគំរោង ចំនួន ៤៣ របស់រដ្ឋាភិបាល ។ ចំណែកឯ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាបានវាយតម្លៃនៅក្នុងរបាយណ៏ការសិក្សាស្រាវជ្រាវរបស់ខ្លួនថា "ការចំណាយក្រៅផ្លូវការ ដែលបង់ដោយសហគ្រាសឯកជនមានប្រមាណ ៣៣០លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥" ។ របាយការណ៏វាយតម្លៃនេះ ក៏បានអោយដឹងផងដែរថា "រដ្ឋបាត់បង់ចំណូលពន្ធដល់ទៅ ៤០០ លាន ដុល្លាអាមេរិក នៅក្នុងឆ្នាំ២០០៥ នេះ" ។ ជាមួយគ្នានេះផងដែរនៅឆ្នាំ២០០៦ អាជ្ញាធរបានរារាំង និង ឃាត់ខ្លួនមិនអោយធ្វើសកម្មភាពផ្សព្វផ្សាយសារបាតដៃស្អាតស្អំក្នុងន័យរួមគ្នាប្រឆាំងអំពើពុករលួយ ចំនួន ៧ ករណី នៅទីក្រុងភ្នំពេញ ព្រមទាំងដកហូតយកសំភារៈជាឯកសារសំរាប់ផ្សព្វផ្សាយមួយចំនួនផងដែរ ។

កត្តាទាំងនេះ ជាការផ្ទុយពីគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអណត្តិទី៣ ដោយមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រមុខ ដែលបានចាត់ទុកការប្រឆាំងអំពើពុករលួយគឺជាស្នូល នៃ យុទ្ធសាស្រ្តចតុកោណសំរាប់ការលូតលាស់, ភាពមានការងារធ្វើ, សមភាព និង ប្រសិទ្ធិភាព ។

អំពើពុករលួយនាពេលបច្ចុប្បន្ននេះត្រូវបានគេមើលឃើញថា វាបានធ្វើអោយខ្ទេចខ្ទាំដល់វិស័យទាំងឡាយរបស់សង្គមដូចជាៈ

អំពើពុករលួយនៅក្នុងវិស័យនយោបាយវាបំផ្លិចបំផ្លាញប្រជាធិបតេយ្យ និង អភិបាលកិច្ចល្អ ដោយរំលោភ ឬ ធ្វើវិទ្ធង្សនាលើនិតិវិធីផ្លូវការ ។ អំពើពុករលួយនៅក្នុងការបោះឆ្នោត និង នៅក្នុងអង្គនីតិបញ្ញត្តិកាត់បន្ថយការទទួលខុសត្រូវ និង ធ្វើអោយខូចភាពជាតំណាងនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ អំពើពុករលួយនៅក្នុងតុលាការធ្វើអោយគ្រោះថ្នាក់ដល់ធម្មាធិបតេយ្យ ។ អំពើពុករលួយនៅក្នុងរដ្ឋបាលសាធារណៈ ធ្វើឱ្យគ្មានយុត្តិធម៌ដល់ការផ្តល់សេវាកម្ម លើសពីនេះទៀតវាធ្វើអោយរេចរិលដល់សមត្ថភាពស្ថាប័នរបស់រដ្ឋាភិបាល ដូចជានីតិវិធីមិនត្រូវបានគេគោរព ធនធានមនុស្សគ្មានឱកាសផ្ទេរចំណេះដឹង ហើយការិយាល័យសាធារណៈត្រូវបានគេទិញ និង លក់ ។ ជាមួយគ្នានេះដែរ អំពើពុករលួយបានធ្វើអោយខូចខាតដល់ភាពស្របច្បាប់របស់រដ្ឋាភិបាល ហើយតម្លៃខាងប្រជាធិបតេយ្យមិនត្រូវបានគេជឿជាក់ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មសូមធ្វើអនុសាសន៏ទៅកាន់រដ្ឋាភិបាលដូចខាងក្រោមក្នុងការពន្លឿនច្បាប់ប្រឆាំងអំពើពុករលួយគឺ :

<u>ទី១:</u> សេចក្តីព្រាងច្បាប់នេះ ត្រូវតែបង្កើតឱ្យមានអង្គភាពប្រឆាំងអំពើពុករលួយមួយឯករាជ ។ អង្គភាពនេះ

ត្រូវតែមានអណត្តិធ្វើការស៊ើបអង្កេតអំពីបុគ្គលណាក៏ដោយ ដោយមិនគិតអំពីនិន្នាការនយោបាយ ឬ ផលប្រយោជន៍អ្វីទាំងអស់ ។ ជាការពិតហើយថា អង្គភាពប្រឆាំងអំពើពុករលួយនេះអាចទទួលដំបូន្មាន ឬ ការណែនាំពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់ប្រឆាំងអំពើពុករលួយ ក៏ប៉ុន្តែអគ្គលេខាធិការ និង អគ្គលេខាធិការដ្ឋានត្រូវរក្សានូវការត្រួតត្រាលើអង្គភាពនេះជាដរាប ។ ប្រការនេះ រាប់បញ្ចូលទាំងថវិកាស្វ័យត ពោលគឺការតម្រូវឱ្យមានការបើកសាច់ប្រាក់ចំណាយប្រចាំឆ្នាំ នៅរៀងរាល់ដើមឆ្នាំ ផងដែរ ។

<u>**ទី២:**</u> អង្គភាពប្រឆាំងអំពើពុករលួយត្រូវមានអំណាចដើម្បីដឹកនាំការស៊ើបអង្កេតដោយឯករាជ ។ អ្នកធ្វើការស៊ើបអង្កេតប្រឆាំងអំពើពុករលួយ ត្រូវតែជានគរបាលយុត្តិធម៌ ដែលមានអំណាច និងភារកិច្ចជាប៉ូលីសពេញលេញ ហើយនគរបាលទាំងនោះមិនត្រូវទទួលខុសត្រូវចំពោះមុខអគ្គព្រះរាជអាជ្ញាឡើយ ពោល គឺត្រូវទទួលខុសត្រូវចំពោះមុខតែអគ្គលេខាធិការប៉ុណ្ណោះ ។ ប្រការនេះមានសារសំខាន់ណាស់ ដើម្បីការពារដល់សមត្ថភាព នៃអង្គភាពប្រឆាំងអំពើពុករលួយ ។ ពួកគេត្រូវតែមានអាណត្តិឯករាជ ដើម្បីស៊ើបអង្កេតករណីពុករលួយណាមួយក៏ដោយ ហើយមិនត្រូវទទួលការរាំងខ្ទប់ពីសំណាក់ការិយាល័យរបស់ព្រះរាជអាជ្ញា ឡើយ ។

<u>**ទី៣:**</u> ការប្រកាសទ្រព្យសម្បត្តិ ដោយមន្ត្រីរាជការ ត្រូវតែធ្វើឡើងក្នុងលក្ខណៈពេញលេញ និងទាំងស្រុង ។ ជាថ្មីម្តងទៀត ត្រង់ប្រការនេះ យើងខ្ញុំស្នើសុំ សម្តេច ព្រះអង្គម្ចាស់ អ្នកអម្ចាស់ លោកជំទាវ និង ឯកឧត្តម ជាសមាជិក សមាជិកា នៃរដ្ឋសភាជាតិ ធ្វើជាគំរូតែម្តង ។ ករណីដែល សម្តេច ព្រះអង្គម្ចាស់ អ្នកអម្ចាស់ លោកជំទាវ និង ឯកឧត្តម ជាសមាជិក-សមាជិកា នៃរដ្ឋសភាជាតិ បានទទួលសន្លឹកឆ្នោតសម្តែងការជឿទុកចិត្តពីម្ចាស់ឆ្នោត នេះមានន័យថា សម្តេច ព្រះអង្គម្ចាស់ អ្នកអម្ចាស់ លោកជំទាវ និង ឯកឧត្តម ត្រូវតែមានតម្លាភាពពេញបរិបូរណ៍នៅក្នុងកិច្ចការហិរញ្ញវត្ថុរបស់លោក ។ ជាមួយគ្នានេះដែរ ដើម្បីឱ្យអង្គភាពប្រឆាំងអំពើពុករលួយអាចអនុវត្តការងាររបស់ខ្លួនបាន ការប្រកាសទ្រព្យសម្បត្តិត្រូវតែរាប់បញ្ចូលនូវ ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធមន្ត្រី និងកូនៗ ផងដែរ ហើយឯកសារប្រកាសទ្រព្យសម្បត្តិនោះ ត្រូវតែអនុញ្ញាតឱ្យបើកមើលបានក្នុងអំឡុងពេលស៊ើបអង្កេត ។

<u>**ទី៤ និង ចុងក្រោយ:**</u> ច្បាប់ប្រឆាំងអំពើពុករលួយនេះ ត្រូវតែមានបទបញ្ញត្តិស្តីពីបទល្មើសព្រហ្មទណ្ឌស្របគ្នានឹងក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌ ។ ត្រង់នេះ មានន័យថាបទបញ្ញត្តិស្តីពីការលាក់ការណ៍សម្ងាត់ត្រូវឱ្យមានភាពរឹងមាំ និង ខ្លាំង ដើម្បីការពារជនរងគ្រោះ និង សាក្សី ។ ហើយទាក់ទងទៅនឹងការស៊ើបអង្កេតច្បាប់នេះត្រូវមានលក្ខណៈជាច្បាប់ពិសេស ។

ដរាបណាច្បាប់ប្រឆាំងអំពើពុករលួយនេះ នៅមិនអនុលោមទៅតាមស្តង់ដារអន្តរជាតិជាគន្លឹះ ដូចដែលបានលើកឡើងខាងលើនេះទេ ដរាបនោះច្បាប់នេះក៏មិនខុសអ្វីពីខ្លាក្រដាសនោះឡើយ ពោលគឺមើលទៅឃើញហាក់ដូចជាខ្លាំង ក៏ប៉ុន្តែធាតុពិតគឺគ្មានអំណាច ។

## III. <u>បញ្ហាសិទ្ធិបញ្ចេញមតិ</u>

ការព្រួយបារម្ភចំពោះការរឹតបន្តឹង ការគាបសង្កត់លើសេរីភាពក្នុងបញ្ចេញមតិ ឬ ការជួបប្រជុំ ការប្រើអំពើហិង្សាប្រឆាំងទៅលើអ្នកដើរដង្ហែក្បួន ឬ អ្នកធ្វើបាតុកម្ម និង កូដកម្ម ដោយសន្តិវិធី នៅតែបន្ត ។ ការស្នើសុំធ្វើបាតុកម្ម ឬ ការជួបប្រជុំ មិនសូវបានទទួលការអនុញ្ញាតិទេ ឬ ត្រូវបំបែកដោយកងកំលាំង និង ពីសំណាក់អាជ្ញាធរមូលដ្ឋាន ។ ទាំងនេះគឺជាបញ្ហាឧបសគ្គគន្លឹះក្នុងគោលការណ៍គោរពសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម ស្នើសុំឱ្យមានការគោរពច្បាប់ដែលមានជាធរមាន ជាពិសេសច្បាប់ដែលផ្តល់សិទ្ធិសេរីភាពទូលំទូលាយក្នុងការធ្វើបាតុកម្មអហិង្សា និង សេរីភាពនៃការបញ្ចេញមតិ ដើម្បីលើកស្ទួយដល់នីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

## IV. សិទ្ធិទទួលការការពាររបស់បុគ្គលិកសិទ្ធិមនុស្ស

ការងាររបស់បុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាល ពិសេសអង្គការសិទ្ធិមនុស្សគឺជាវិភាគទានដ៏សំខាន់ក្នុងការចូលរួមចំណែកសាងសន្តិភាព និង អភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយអត្ថន័យ និង និរន្តភាព ។ ទោះបីជាសកម្មជនសិទ្ធិមនុស្ស និង អ្នកដឹកនាំអង្គការសង្គមខ្លះត្រូវបានដោះលែងកាលពីដើមឆ្នាំ២០០៦នេះក៏ដោយ ក៏យើងសង្កេតឃើញថា ឆ្នាំនេះនៅមានការគំរាមកំហែងជាបន្តបន្ទាប់មកលើសកម្មជនសិទ្ធិមនុស្ស ដែលបានចុះស៊ើបអង្កេតស្រាវជ្រាវករណីរំលោភសិទ្ធិមនុស្សនានា ហើយនៅពេលថ្មីៗបំផុតនេះ មានការគំរាមកំហែងសំលាប់ទៅលើ លោក **ប៉ែន ប៊ុណ្ណា** អ្នកសំរបសំរួលសមាគមការពារសិទ្ធិមនុស្សអាដហុក ប្រចាំខេត្តរតនគីរី ។ មានករណីខ្លះអាជ្ញាធរបានឃាយឃាំងមិនឱ្យសកម្មជនសិទ្ធិមនុស្សចុះទៅដល់ទីកន្លែងកើតហេតុ ដែលកើតមានបញ្ហារំលោភសិទ្ធិមនុស្សទេ ពិសេសលើករណីរំលោភសិទ្ធិដីធ្លី ។ សកម្មជនសិទ្ធិមនុស្សត្រូវបានរងការចោទប្រកាន់ពីសំណាក់អាជ្ញាធរខ្លះថា ជាអ្នកញុះញ៉ង់ប្រជាពលរដ្ឋឱ្យប្រឆាំងនឹងការសំរេចរបស់អាជ្ញាធរ ដោយអាជ្ញាធរមិនព្រមទទួលស្គាល់ថា ការសំរេចរបស់ខ្លួនធ្វើឱ្យប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋហើយពួកគាត់មិនពេញចិត្ត និង នាំគ្នាតវ៉ានោះទេ បែរជាថាមកពីក្រុមសិទ្ធិមនុស្សទៅវិញ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មសូមជំរុញដល់រាជរដ្ឋាភិបាលទទួលស្គាល់ និង ចាត់ទុកថា ការងាររបស់សង្គមស៊ីវិលគឺប្រកបដោយលក្ខណៈច្បាប់ និង មានតំលៃសំរាប់សង្គមខ្មែរ ព្រមទាំងធានាឱ្យរាល់សកម្មភាពការងាររបស់អង្គការសិទ្ធិមនុស្សជៀសផុតការគំរាមកំហែងនានា ពីសំណាក់មន្ត្រីរដ្ឋាភិបាល ដែលក្នុងនោះតំរូវចាំបាច់ឱ្យក្រុមការងារសិទ្ធិមនុស្ស ឬ សង្គមស៊ីវិលបំពេញការងារដោយគ្មានការរារាំង និងគ្មានការភ័យខ្លាច ពីសុវត្ថិភាពរបស់ខ្លួន ។

គណៈកម្មាធិការប្រព្រឹត្តិកម្មសង្ឃឹមថាសង្គមស៊ីវិល និង រាជរដ្ឋាភិបាល ជាដៃគូល្អនឹងគ្នាក្នុងការកសាងកម្ពុជាឱ្យក្លាយជាប្រទេសនីតិរដ្ឋ និង លើកតំកើង ការគោរពសិទ្ធិមនុស្ស ។

## V. អំពើហឹង្សានយោបាយ និង ការបោះឆ្នោត

ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាដំណាក់កាលដ៏សំខាន់ ឆ្ពោះទៅរកការកសាងលទ្ធិប្រជាធិបតេយ្យដ៏ផូរផង់នៅកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយគណៈកម្មាធិការប្រព្រឹត្តិកម្មបានសង្កេតឃើញថា អំពើឃាតកម្ម ការគំរាមកំហែង ការបំភិតបំភ័យ និងការយាយីផ្នែកនយោបាយ បាន និងកំពុងតែកើនឡើងក្នុងពេលដែលប្រទេសកម្ពុជាកំពុងដំណើរការរៀបចំការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ២០០៧ ខាងមុខនេះ ។ ការគំរាមកំហែងបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់បរិយាកាសសន្តិសុខ សេរីភាពរបស់ប្រជាពលរដ្ឋក្នុងចូលរួមដំណើរការបោះឆ្នោត និងសកម្មភាពនយោបាយ នៅក្នុងដំណាក់កាលមុនការបោះ-ឆ្នោត ។ ជាក់ស្តែងមចាប់តាំងពីពេលចែកប័ណ្ណព័ត៌មាន ពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោត ឆ្នាំ២០០៦ មកដល់ពេលបច្ចុប្បន្ននេះមានអំពើហឹង្សាទាក់ទិនសកម្មជនគណបក្សនយោបាយនៅខេត្តចំនួនបី គឺ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តក្រចេះ ក្នុងនោះអំពើឃាតកម្មចំនួនបី (០៣)ករណី (ស្លាប់មនុស្សចំនួន០៣នាក់) ទៅលើសកម្មជនគណបក្ស សម រង្ស៊ី ដែល២ករណី កើតឡើងនៅក្នុងខេត្តព្រៃវែង ១ករណីនៅក្នុងខេត្តកំពង់ចាម និងករណី ឃាតកម្មមិនបានសំរេចមួយ(០១)ករណីទៀតទៅលើកម្មជនគណបក្ស ហ៊្វុន ស៊ិនប៉ិច ក្នុងខេត្តក្រចេះ ។ ករណីបង្កឱ្យមានរបួសស្នាមទៅលើសកម្មជនគណបក្ស សម រង្ស៊ី ចំនួនបី (០៣)ករណី ដែល២ករណីកើតឡើងនៅខេត្តព្រៃវែង និង ១ករណីទៀតនៅខេត្តកំពង់ចាម ។ រីឯករណីទំលាក់ផ្លាកគណបក្សនយោបាយមានមួយ (០១)ករណី នៅក្នុងខេត្តកំពង់ចាមទៅលើគណបក្ស ហ៊្វុន ស៊ិនប៉ិច ។ សកម្មជនគណបក្សនយោបាយ ដែលទទួលរងនូវអំពើឃាតកម្មពីសំណាក់ឧក្រិដ្ឋជន សុទ្ធតែជាមនុស្សដែលមានប្រជាប្រិយភាពនៅក្នុងមូលដ្ឋានពួកគាត់រស់នៅ និង រយៈពេលចុងក្រោយនេះពួកគាត់បានធ្វើសកម្មភាព អូសទាញប្រជាពលរដ្ឋរស់នៅក្បែរខាងគ្នាឱ្យចុះចូលជាមួយគណបក្សរបស់

ពួកគាត់ និងបានចូលរួមយ៉ាងសកម្មក្នុងដំណាក់កាល ពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះ ដូចជាការចែកទំរង់ ១០១៨ និង ការថតរូបសំរាប់បិទទំរង់បែបបទចុះឈ្មោះជាដើម ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ប្រសិនបើអំពើហឹង្សានយោបាយនៅមានជាបន្ត វាជាបច្ច័យអាក្រក់ប៉ះពាល់ដល់ដំណើរការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរី និង យុត្តិធម៌ នាពេលខាងមុខ ចំណែកឯប្រជាពលរដ្ឋ និង បេក្ខជនឈរឈ្មោះបោះឆ្នោត នឹងមានការភ័យខ្លាចមិនហ៊ានចូលរួមក្នុងសកម្មភាពនយោបាយពេញលេញទេ ពិសេសនៅក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ ។

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ បានមានប្រសាសន៍ថា "ដើម្បីកាត់បន្ថយការរំលោភបំពានសិទ្ធិ និង រារាំងដល់ជនដទៃទៀតមិនឱ្យប្រព្រឹត្តបទរំលោភសិទ្ធិមនុស្ស គឺមានតែការផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តិបទរំលោភសិទ្ធិមនុស្ស" ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមស្នើដោយទទូចដល់រាជរដ្ឋាភិបាល សូមមេត្តាចាត់វិធានការប្រកបដោយប្រសិទ្ធិភាព និង ជាបន្ទាន់ ដើម្បីការពារ និង បង្ការកុំឱ្យកើតមានអំពើហឹង្សានយោបាយជាបន្តទៀត និង ធានាដល់សិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ ។ ចំណែកតុលាការ កងកំលាំងប្រដាប់អាវុធ និង អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែធានាឱ្យបាននូវឯករាជ្យភាព និង អព្យាក្រឹត្យ ក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួនក្នុងគោលបំណងដើម្បីបង្កើតបរិយាកាសនយោបាយល្អ ក្នុងអំឡុងពេលបោះឆ្នោត ។

## VI. <u>បញ្ហាភាពក្រីក្រ</u>

ភាពក្រីក្រគឺជាបញ្ហាដ៏ធំមួយនៅក្នុងសង្គមជាតិយើង ។ ភាពក្រីក្រមិនមែនជាផលកម្មអាក្រក់មកពីជាតិមុននោះទេ ភាពក្រីក្រគឺជាបញ្ហាសិទ្ធិមនុស្ស ការរំលោភសិទ្ធិមនុស្សគឺជាមូលហេតុផង និង ជាផលវិបាកនៃភាពក្រីក្រផង។ ការរំលោភយកដីធ្លី ឬ ផ្ទះសំបែង ដែលជាការរំលោភសិទ្ធិមនុស្សដ៏សំខាន់មួយនោះបានធ្វើឱ្យប្រជាពលរដ្ឋធ្លាក់ខ្លួនក្រភ្លាមមួយរំពេច ឬក្រជាងមុន ។ អ្នកខ្លះចោទថា មកពីប្រជាជននោះខ្ជិលដែលបណ្តាលឱ្យក្រ ដោយគេមិនបានទទួលស្គាល់ថា ពួកគាត់គ្មានឱកាសនោះទេ ពេលខ្លះពួកគាត់មានការខិតខំណាស់ដែរ តែមិនបានផលដូចការរំពឹងទុក ។

ការបំបាត់ភាពក្រីក្រមិនមែនចាំទាល់តែប្រទេសមានចំណូលខ្ពស់សិន តែមួយមុខនោះទេ មានប្រទេសខ្លះមានចំណូលច្រើន តែចំណូលទាំងនោះបានទៅលើតែជនមួយក្រុមតូច ប្រទេសនោះនៅតែក្រីក្រដដែល ។ ប្រការនេះ គឺមកពីគ្មានសមធម៌ក្នុងសង្គម ។ ការកាត់បន្ថយភាពក្រីក្រគឺមិនអាចពឹងតាមរយៈការចែកអំណោយមនុស្សធម៌តែមួយមុខនោះទេ គឺត្រូវមានផែនការអភិវឌ្ឍន៍មួយត្រឹមត្រូវ និង យកចិត្តទុកដាក់អនុវត្តន៍ឱ្យមានប្រសិទ្ធិភាពលើផែនការនោះ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ដើម្បីកាត់បន្ថយភាពក្រីក្រគឺមានវិធីសាស្រ្តដូចជា រួមគ្នាបំបាត់អំពើពុករលួយ ការស៊ីសំណូកគ្រប់ប្រភេទ ការកេងប្រវ័ញ្ច ការរើសអើង លើកស្ទួយឱ្យមានការចូលរួមពីស្ត្រីក្នុងជីវភាពគ្រួសារ និង រាល់កិច្ចការសង្គម ។ ជំរុញការកសាងនូវរាល់ហេដ្ឋារនាសម្ព័ន្ធដែលជាតំរូវការចាំបាច់របស់ប្រជាពលរដ្ឋទូទៅ លើកកំពស់ ការគោរពសិទ្ធិមនុស្ស សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាដើម ។

ភ្នំពេញ, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៦


**<u>ពត៌មានបន្ថែមសូមទាក់ទង</u> :**

-លោក **ធន សារាយ** ប្រធានសម្របសម្រួល គណៈកម្មាធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគមអាដហុក
ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩

-លោកស្រី វេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ ទូរស័ព្ទលេខ: ០១២ ៨០២ ៥០៦

-លោក **សុក សំអឿន** នាយកប្រតិបត្តិអង្គការ CDP ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩

-លោក **យង់ គិមអេង** ប្រធានមជ្ឈមណ្ឌល PDP-Center ទូរស័ព្ទលេខ: ០១៦ ៨២៨ ២១១

-លោកស្រី **ណៃ ឌីណា** នាយិកាប្រតិបត្តិ KID ទូរស័ព្ទលេខ: ០១១ ៩២៤ ២៨៦